ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ០៦២/២៣ អអរ

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រះសីហនុ"

ព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រះសីហនុ»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម គួច ចំរើន អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តព្រះសីហនុ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តព្រះសីហនុ ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តព្រះសីហនុ មានផ្ទៃដីសរុប ២.៦៥៨,៩០គីឡូម៉ែត្រការ៉េ ចែកចេញជា ២ក្រុង ៣ស្រុក ២៣ឃុំ និង៦សង្កាត់ មានភូមិចំនួន១១១ភូមិ មានប្រជាពលរដ្ឋសរុបចំនួន ៥០.៥២២គ្រួសារ ស្មើនឹង ២២៩.៣៣២នាក់ ដោយមានវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ និងកសិកម្ម ដែលជា

វិស័យអាទិភាពសម្រាប់ការអភិវឌ្ឍឿនសេដ្ឋកិច្ចជាតិ។ ក្នុងនោះ ប្រជាពលរដ្ឋប្រកបមុខរបរកសិកម្ម ជាចម្បងមាន ២៣,៦០% សិប្បកម្ម ១,៨០% និងសេវាកម្ម ៧៤,៦០% ចំណូលប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់ៗមានចំនួន ៤.១៨០ដុល្លារអាមេរិក ធ្វើឱ្យអត្រាភាពក្រីក្រថយចុះមកត្រឹម ១,៨៦%។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ រដ្ឋបាលខេត្តព្រះសីហនុ សម្រេចបាននូវសមិទ្ធផលការងារសំខាន់ៗ រួមមាន៖

- **វិស័យគាំពារសង្គម៖** ក្នុងការស្តារលទ្ធភាព និងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសក្នុងពេលជួបប្រទះនឹងវិបត្តិសង្គម សម្ពាធអតិផរណា ក៏ដូចជាជំងឺកូវីដ-១៩ រដ្ឋបាលខេត្តបានអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ចំណាយថវិកាសរុបចំនួន ៤៣.១៦៩.៧១២.០០០រៀល, ស្ត្រីមានផ្ទៃពោះ និងកុមារ ចំណាយថវិកា ១.៣៧៩.៤៨០.០០០ រៀល, កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសាររងហានិភ័យសម្ពាធអតិផរណា ចំណាយថវិកា ១០.១៣.៩៦៤.៤០០រៀល, កម្មវិធីជំនួយសង្គមឧបត្ថម្ភដល់កម្មករនិយោជិត ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ចំណាយថវិកា ២.៦៤៧.២៨៦.៨៥០រៀល និងបានអនុវត្តកម្មវិធី ប.ស.ស សម្រាប់មន្ត្រីរាជការស៊ីវិល ចំណាយថវិកា ២៦.៨១១.៥៦១.១៤០រៀល និងសម្រាប់អតីតយុទ្ធជន ចំណាយថវិកា ២១.៨១៩.៩០១.៥៩១រៀល។
- **វិស័យទេសចរណ៍៖** ជាខេត្តដែលមានឆ្នេរសមុទ្រស្រស់ស្អាត សម្បូរដោយធនធានធម្មជាតិ កោះ និងត្រូវបានប្រសិទ្ធនាមថា **"តារារះនាទិសនារតី"** ការងារទេសចរណ៍នេះ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខេត្តទាំងមូល ដោយភ្ញៀវទេសចរមកកម្សាន្តក្នុងខេត្តសរុបចំនួន ១១.៥០៥.៤០៦នាក់ ក្នុងនោះភ្ញៀវជាតិ ៩.៣៨៥.២២៨នាក់ និងភ្ញៀវអន្តរជាតិ ២.១២០.១៧៨នាក់ ផ្តល់ការងារផ្ទាល់ ដល់ប្រជាពលរដ្ឋសរុប ៧.៩៧២នាក់។
- **ការងារសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងការផ្តល់សេវាសាធារណៈ៖** រដ្ឋបាលខេត្ត បានខិតខំអនុវត្តនូវនយោបាយកំណែទម្រង់ការផ្តល់សេវាសាធារណៈ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់បំផុត តាមរយៈការបន្តពង្រឹង និងពង្រីកយន្តការច្រកចេញ ចូលតែមួយ សំដៅធ្វើយ៉ាងណា បង្កិតការផ្តល់សេវាឱ្យកាន់តែកៀក និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋឆាប់រហ័សបំផុត។ ជាក់ស្តែង រដ្ឋបាលខេត្តបានបានផ្តល់សេវា សរុបចំនួន ៥៤.៩៥៧សេវា និងប្រមូលចំណូលសរុប ២៧.៦២៨.៨៩៤.៨០០រៀល។ ទន្ទឹមនឹងនោះ ខេត្តក៏រក្សាបាននូវសន្តិសុខ

សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គមមានលក្ខណៈល្អប្រសើរ ដោយកាត់បន្ថយបាននូវគ្រោះថ្នាក់ ហានិភ័យសង្គម ល្បែងស៊ីសង បទល្មើសគ្រប់ប្រភេទ ពិសេសបទល្មើសបច្ចេកវិទ្យា។

- **វិស័យកសិកម្ម៖** ជាវិស័យចូលរួមក្នុងការលើកកម្ពស់សក្តានុពលសេដ្ឋកិច្ច ខេត្តក៏បានជំរុញផលិតកម្មដំណាំកសិកម្មដោយក្នុងរយៈពេល ៥ឆ្នាំ (២០១៨-២០២២) រួមមាន៖ ដំណាំស្រូវទទួលបានទិន្នផល ចំនួនសរុប ១៨៣.៩៤១តោន ដំណាំសាវប្បកម្មសរុបបាន ១២៧.៩៤៨តោន ដំណាំឧស្សាហកម្មសរុបបាន ១.២៤៤. ៩៩៥តោន ដំណាំកៅស៊ូសរុបបាន ១១.៤១២តោន។ រដ្ឋបាលខេត្តក៏បានលើកកម្ពស់ការការពារធនធានជលផល ដោយពង្រឹង និងគ្រប់គ្រងសហគមន៍នេសាទ ចំនួន៧៥ ទទួលបានបរិមាណផលវារីវប្បកម្ម ចំនួនសរុប ៦.១៨៧តោន បរិមាណផលកែច្នៃផលជលផលចំនួនសរុប ៨.៩៣០តោន។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល និងការចូលរួមវិនិយោគពីវិស័យឯកជន រដ្ឋបាលខេត្តបានអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធ ទាំងការស្ថាបនាពង្រីក និងជួសជុលថែរក្សា ផ្លូវថ្នល់ក្នុងខេត្ត និងនៅតាមបណ្តាក្រុង ស្រុក, ការរៀបចំសោភ័ណភាពទីក្រុង ការកែលម្អតំបន់ឆ្នេរសមុទ្រ ដើម្បីទាក់ទាញភ្ញៀវទេសចរបន្ថែម ការសាងសង់បន្ទប់ទឹកសាធារណៈប្រណិត ជាពិសេស គឺបានសាងសង់ប្រព័ន្ធលូរំដោះទឹក ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់ និងស្ថានីយបូមទឹកកខ្វក់ ក្នុងការកែប្រែគុណភាពទឹកឱ្យមានភាពល្អប្រសើរឡើង។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានដាក់ចេញនូវទិសដៅការងារសំខាន់ៗ ដើម្បីបន្តអភិវឌ្ឍន៍ខេត្ត ដែលរួមមាន៖

- បន្តអនុវត្តគោលនយោបាយភូមិ-ឃុំ/សង្កាត់ មានសុវត្ថិភាព
- បន្តលើកម្ពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាល ដោយពង្រីកវិសាលភាពសេវាកម្ម ផ្តល់ដោយរដ្ឋបាលខេត្ត ឱ្យបានទូលំទូលាយ
- បន្តបង្វិតរដ្ឋបាលឱ្យនៅកៀកជិតនឹងប្រជាពលរដ្ឋ បង្កភាពងាយស្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ឱ្យបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព
- បន្តខិតខំរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ នៅតាមបណ្តាផ្លូវ បណ្តោយឆ្នេរ និងទីសាធារណៈក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ ដើម្បីរក្សាបាននូវបរិស្ថានស្អាត និងសោភ័ណភាពទីក្រុងស្អាត
- បន្តផ្សព្វផ្សាយពីវិធានការ ការពារ ទប់ស្កាត់ គ្រប់គ្រង និងប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ឱ្យបានទាន់ពេលវេលា និងបន្តយុទ្ធនាការកិច្ចការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ឱ្យបានគ្រប់ផែនការ
- បន្តអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា។

## IV. សម្គាល់

ក្នុងរយៈពេល ៥ឆ្នាំនេះកន្លងមកនេះ ខេត្តព្រះសីហនុមានការរីកចម្រើនយ៉ាងខ្លាំង ពិសេសគឺការរីកដុះដាលនៃសំណង់អាគារខ្ពស់ៗ ការបង្កើតឱ្យមានតំបន់សេដ្ឋកិច្ចពិសេស កំពង់ផែសមុទ្រទឹកជ្រៅ និងការអភិវឌ្ឍនៅតាមបណ្តាកោះនានាទូទាំងខេត្តផងដែរ។ សូមបញ្ជាក់ផងដែរថា សំណង់អាគារសរុបក្នុងខេត្តមានចំនួន ១០០៦អាគារ និងមានកោះ ចំនួន៣០ ថ្មប៉ប្រះទឹក ចំនួន២។ ការអនុវត្តគម្រោងវិនិយោគទូទាំងខេត្តមានចំនួន ១.១៨៦គម្រោង ក្នុងនោះ បានបញ្ចប់ ៥៩៥គម្រោង។ ក្នុងនោះផងដែរ រាជរដ្ឋាភិបាល បានផ្តល់ការវិនិយោគទៅលើកោះ និងឆ្នេរ ដល់ក្រុមហ៊ុនចំនួន ២៧ ដែលមានទុនវិនិយោគសរុប ៨.៩០០.៥៧០.២៥១ដុល្លារអាមេរិក និងមានគម្រោងវិនិយោគទៅលើវិស័យឧស្សាហកម្ម ដោយការកែច្នៃម្ហូបអាហារ ដែលមានទុនវិនិយោគសរុប ១.៧៥៣.៩០០ដុល្លារអាមេរិក៕

ថ្ងៃពុធ ១០រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣